ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១២ លេខ ៤៤ សប្តាហ៍ទី ២ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១២

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

p

p

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥២០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ សប្បុរសជន ចំនួន ០៣ រូប ៤២៥៧

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥២១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ អង្គភាព ចំនួន ០២ ៤២៥៨

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥២២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ ព្រះតេជគុណថេរប្បញ្ញោ **ឆយ ច័ន្ទថូ** ៤២៥៩

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥២៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ និង សាស្ត្រាចារ្យ ចំនួន ១២២ រូប ៤២៦០

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥២៤ ស្តីពី ការតម្លើងឋានៈឯកឧត្តម **ពេជ សារឿន** ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៤២៦៥

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥២៥ ស្តីពី ការប្រគល់ភារកិច្ចជូនឯកឧត្តម **គួប ចាន់នី** ឱ្យបំពេញមុខងារជានាយកខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក ៤២៦៦

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥២៦ ស្តីពី ការប្រគល់ភារកិច្ចជូនឯកឧត្តម **សុខ សូតាន** ឱ្យបំពេញមុខងារជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៤២៦៧

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥២៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម អស់លោក លោកស្រី មន្ត្រីរាជការ នៅខេត្តបន្ទាយមានជ័យ ចំនួន ២៧ រូប ៤២៦៨

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥២៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ ឯកឧត្តមថ្នាក់ដឹកនាំក្រុងគិនថឺ និង ខេត្តហ៊ូវយ៉ាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ជាខេត្តសម្ព័ន្ធមេត្រីភាពជាមួយខេត្តកំពង់ឆ្នាំង ចំនួន ០២ រូប ៤២៧០

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥២៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ ព្រះសង្ឃ ចំនួន ០៤ អង្គ ជាព្រះចៅអធិការវត្ត ៤២៧១

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥៣០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឯកឧត្តម **សៀង លុនទ្រី** ៤២៧២

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥៣១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ លោកជំទាវ **ធេព សារិន** **អ៊ុង សំខាន់** ៤២៧៣

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥៣២ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **ផាង ពៅ** នាយនគរបាលជាតិជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ៤២៧៤

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥៣៣ ស្តីពី ការតែងតាំង ឯកឧត្តម លោកជំទាវ ជាទីប្រឹក្សា និង ជំនួយការ លោកជំទាវ **ឃួន សុដារី** អនុប្រធានទី ២ នៃរដ្ឋសភា ចំនួន ០៥ រូប ៤២៧៥

II_រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

០៧-៦-២០១២ -អនុក្រឹត្យលេខ ៨២ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.១២៩ ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្រ្ត ខេត្តព្រះវិហារ ៤២៧៧

០៧-៦-២០១២ -អនុក្រឹត្យលេខ ៨៣ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១.៨៦៥ ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្រ្ត ខេត្តឧត្តរមានជ័យ ៤២៧៩

០៧-៦-២០១២ -អនុក្រឹត្យលេខ ៨៤ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១.១៩៥ ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្រ្ត ខេត្តឧត្តរមានជ័យ ៤២៨១

០៧-៦-២០១២ -អនុក្រឹត្យលេខ ៨៥ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.៤៧៧ ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃភ្នំណាមលៀវ ស្ថិតនៅក្នុងភូមិសាស្រ្ត ខេត្តមណ្ឌលគិរី ៤២៨៣

០៧-៦-២០១២ -អនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៤.០៩៥ ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្រ្ត ខេត្តឧត្តរមានជ័យ និង ខេត្តព្រះវិហារ ៤២៨៥

០៧-៦-២០១២ -អនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩៧០០ ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្រ្ត ខេត្តឧត្តរមានជ័យ និង ខេត្តព្រះវិហារ ៤២៨៧

គ

១១-៦-២០១២ -អនុក្រឹត្យលេខ ៨៨ អនក្រ.បក ស្ដីពី ការកែសម្រួលអត្រាអាករពិសេស និង អត្រាអាករនាំចេញលើទំនិញមួយចំនួន ៤២៨៩

០៦-៦-២០១២ -អនុក្រឹត្យលេខ ៦៥៥ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៤២៩២

០៦-៦-២០១២ -អនុក្រឹត្យលេខ ៦៥៦ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៤២៩៣

០៦-៦-២០១២ -អនុក្រឹត្យលេខ ៦៥៧ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤២៩៤

០៦-៦-២០១២ -អនុក្រឹត្យលេខ ៦៥៨ អនក្រ.តត ស្ដីពី ការតម្លើងថ្នាក់តាមសញ្ញាបត្រជូនមន្ត្រីរាជការ ៤២៩៥

០៦-៦-២០១២ -អនុក្រឹត្យលេខ ៦៥៩ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ និង តែងតាំងមន្ត្រីរាជការ ៤២៩៧

០៧-៦-២០១២ -អនុក្រឹត្យលេខ ៦៦០ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤២៩៩

០៧-៦-២០១២ -អនុក្រឹត្យលេខ ៦៦១ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤៣០០

០៧-៦-២០១២ -អនុក្រឹត្យលេខ ៦៦២ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៤៣០២

០៨-៦-២០១២ -អនុក្រឹត្យលេខ ៦៦៣ អនក្រ.តត ស្ដីពី ការតែងតាំងអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ៤៣០៤

០៨-៦-២០១២ -អនុក្រឹត្យលេខ ៦៦៤ អនក្រ.តត ស្ដីពី ការតែងតាំងអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ៤៣០៦

១១-៦-២០១២ -អនុក្រឹត្យលេខ ៦៦៥ អនក្រ.តត ស្ដីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៤៣០៧

១១-៦-២០១២ -អនុក្រឹត្យលេខ ៦៦៦ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៤៣០៨

១១-៦-២០១២ -អនុក្រឹត្យលេខ ៦៦៧ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤៣០៩

១១-៦-២០១២ -អនុក្រឹត្យលេខ ៦៦៨ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៣១០

១១-៦-២០១២ -អនុក្រឹត្យលេខ ៦៦៩ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៤៣១២

១១-៦-២០១២ -អនុក្រឹត្យលេខ ៦៧០ អនក្រ.តត ស្ដីពី ការជូនគ្រឿងឥស្សរិយយសមេដាយសហមេត្រី ៤៣១៥

១១-៦-២០១២ -អនុក្រឹត្យលេខ ៦៧១ អនក្រ.តត ស្ដីពី ការតែងតាំងមុខតំណែងនាយនគរបាលជាតិ ៤៣១៧

១១-៦-២០១២ -អនុក្រឹត្យលេខ ៦៧២ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤៣១៨

១១-៦-២០១២ -អនុក្រឹត្យលេខ ៦៧៣ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៤៣១៩

១១-៦-២០១២ -អនុក្រឹត្យលេខ ៦៧៤ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៣២៥

១១-៦-២០១២ -អនុក្រឹត្យលេខ ៦៧៥ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៤៣២៩

១១-៦-២០១២ -អនុក្រឹត្យលេខ ៦៧៦ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៣៣៥

២_សារាចរណែនាំ

១២-៦-២០១២ -សារាចរណែនាំលេខ ០៧ សរណន ស្ដីពី ការប្រារព្ធទិវាអតីតយុទ្ធជនកម្ពុជាលើកទី ៥ ៤៣៣៧

III. ការងារបណ្ដាក្រសួង

១. ពីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៣-៤-២០១២ -ប្រកាសលេខ ៤៣៩ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វុនដា អ៊ិនដាសស្ទ្រៀល បង្កើតរោងចក្រ ចាក់សម្លៀកបំពាក់ ៤៣៣៩

២៧-៤-២០១២ -ប្រកាសលេខ ៤៦៥ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេម វើណា ហ្វេសិន បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៤៣៤៣

២៧-៤-២០១២ -ប្រកាសលេខ ៤៦៦ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឃ្យុង-អ៊ិន តិចនិច (ខេមបូឌា) បង្កើតរោងចក្រ ផលិតមីក្រូត្រង់ស្វូអគ្គិសនី ៤៣៤៧

២៧-៤-២០១២ -ប្រកាសលេខ ៤៦៧ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អូរ៉ូរ៉ា អីភែរីល (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៤៣៥១

២៧-៤-២០១២ -ប្រកាសលេខ ៤៦៨ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេច & អិល អីភែរីល (ខេមបូឌា) ខប បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ (កាត់ដេរ,ចាក់,ប៉ាក់) ៤៣៥៥

២. ពីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៩-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៦២ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខ្មែរ ណាហ្គាណូ ម៉ូធ័រ ៤៣៥៩

០៩-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៦៣ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ប្រេន មេឌា សឺវីស ៤៣៦១

០៩-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៦៥ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន គួត ដាត់ យ៉ាញ សួត ខមភេនី ៤៣៦៣

០៩-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៦៦ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហ៊ីលតុន ផាត ទីឡា គ្រុប ៤៣៦៤

០៩-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៦៧ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ឌី.ប៊ី.អេ.ធី. ត្រេឌីង ៤៣៦៦

០៩-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៨០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ប៊្លូ គីស សឺវីស ហូលឌីង ៤៣៦៨

០៩-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៨២ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន មូប៊ីតែល ខមភេនី លីមីធីត ៤៣៧០

p

០៩-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៨៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូ អេហ្គ្រីខលឆឺរល ប្រូឌូស** ៤៣៧២

០៩-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៨៥ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ម៉ូឌែន ថៃម គ្រុប ខូ អិលធីឌី** ៤៣៧៤

០៩-៣-២០១១ -លិខិតបញ្ជាក់លេខ ១៣០០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ារ៉ាឡា ឫទ្ធី គ្រុប** ៤៣៧៦

p

p

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៤០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រទានព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន០៣រូប មានគុណបំណាច់ចំពោះជាតិមាតុភូមិ ដោយបានជួយកសាង
សមិទ្ធផលនានា លើវិស័យព្រះពុទ្ធសាសនា ស្ថិតនៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កន្លងមក

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១-លោក ខេង ស៊ុម
២-លោក ចៅ ម៉េងជួន
៣-លោក អ៊ុំ សុផល

៣៣.០៦០៦.៥៤៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ៥០៥ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល

សូយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៤១

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

ព្រះរាជទាន

ចំពោះ

អង្គភាពចំនួន០២ ដែលមានស្នាដៃល្អក្នុងការចងសម្ព័ន្ធមេត្រីភាពជាមួយយោធភូមិភាគទី៣
ដោយជួយឧបត្ថម្ភថវិកាដល់ការកសាងអគារសាលប្រជុំ ០១ខ្នង ទទួលបានលទ្ធផលល្អប្រសើរ

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍
១-ក្រុមហ៊ុនអានកូ កេមារ៉ែន លីមារ៉ែន
២-សហគ្រាសកោស៊ី វៀតណាម ប្រចាំកម្ពុជា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៣-០៦១២.៥៤៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២

លេខ: ៥០២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១២
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ជូន

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ចំពោះ

ព្រះតេជគុណថេរបញ្ញោ ឆយ ខ្មែរ

ដែលបានចូលរួមជួយកសាង ព្រះវិហារ ឧបដ្ឋានសាលា ឆ្លាងទ្វារ អាងទឹក
និងចាក់ដីក្នុងទីធ្លាវត្ត នៅវត្តជោតនារាម ស្ថិតនៅក្នុងឃុំខ្នុរដំបង ស្រុកជើងព្រៃ ខេត្តកំពង់ចាម

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ពកស-១២០៦-៥៤៨

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១២

លេខៈ ៥០៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី ទីស្តីការរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥២៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយទាហាន នៃកងយោធពលខេមរភូមិន្ទ និងសាស្ត្រាចារ្យ
ចំនួន ១៦៦ រូប មានស្នាដៃល្អក្នុងការបម្រើជាតិមាតុភូមិ កន្លងមក

នូវ

ក_គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ

១-ឧត្តមសេនីយ៍ត្រី **ផាត ចន្ថា** អត្តលេខ ០០០៣៣៦
២-ឧត្តមសេនីយ៍ត្រី **ឈុម ឌូរិទ្ធ** អត្តលេខ ០០០៣១៤
៣-ឧត្តមសេនីយ៍ត្រី **ពេជ្រ សុផា** អត្តលេខ ០០០៣២០
៤-ឧត្តមសេនីយ៍ត្រី **អ៊ុក រតនៈ** អត្តលេខ ០០៥១៤៦
៥-ឧត្តមសេនីយ៍ត្រី **អ៊ីស សាផន** អត្តលេខ ០០២៤១៧
៦-ឧត្តមសេនីយ៍ត្រី **ម៉ែន សាត** អត្តលេខ ០០០៩៩៤
៧-ឧត្តមសេនីយ៍ត្រី **ចិន ម៉ុនរឿន** អត្តលេខ ០០០៦៨៥
៨-ឧត្តមសេនីយ៍ត្រី **ស្តើង សេន** អត្តលេខ ០០០៧២៩
៩-ឧត្តមសេនីយ៍ត្រី **មាន មុន្នី** អត្តលេខ ០០៩៦៦១
១០-ឧត្តមសេនីយ៍ត្រី **ស្រាក់ ម៉ុនថន** អត្តលេខ ០០២៥៥៣
១១-វរសេនីយ៍ឯក **ខួន តារា** អត្តលេខ ០០៨៥៨៥
១២-វរសេនីយ៍ឯក **សាន សារឿន** អត្តលេខ ០០៩៨៤០

ខ_គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

១-ឧត្តមសេនីយ៍ត្រី **ស៊ូ សិរី** អត្តលេខ ០២៦០៣៦
២-ឧត្តមសេនីយ៍ត្រី **ជា សារ៉ាត់** អត្តលេខ ០០២២១៩
៣-ឧត្តមសេនីយ៍ត្រី **នេត្រ ណារ៉ាត** អត្តលេខ ០០០៤៩៨
៤-ឧត្តមសេនីយ៍ត្រី **នេង សុខឿន** អត្តលេខ ០០២២៤៧

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៥-ឧត្តមសេនីយ៍ត្រី	ខឹម	ដេត	អត្តលេខ ០០២២២៤
៦-ឧត្តមសេនីយ៍ត្រី	ពេជ្រ	សំអុន	អត្តលេខ ០០២២៣៥
៧-ឧត្តមសេនីយ៍ត្រី	តោគ	សក្តិ	អត្តលេខ ០០៩៦៥២
៨-ឧត្តមសេនីយ៍ត្រី	ទូ	វិជ្ជល	អត្តលេខ ០០៩២១៣
៩-វរសេនីយ៍ឯក	អេន	ណារ៉ាត់	អត្តលេខ ០០១៣៨៩
១០-វរសេនីយ៍ឯក	សេង	ចំរើន	អត្តលេខ ០២៣៧៩២
១១-វរសេនីយ៍ទោ	ម៉េង	សុក្រិត្យមិត្រា	អត្តលេខ ០២៣៩៨៦

គ_គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

១-ឧត្តមសេនីយ៍ទោ	ឡៀង	សោផាត	អត្តលេខ ០០១៨០៣
២-ឧត្តមសេនីយ៍ទោ	ពៅ	ស៊ីថា	អត្តលេខ ០០០៣២៧
៣-ឧត្តមសេនីយ៍ទោ	ពៅ	សុខា	អត្តលេខ ០០០៨៩៩
៤-ឧត្តមសេនីយ៍ទោ	អ៊ីន	ស៊ីដារ៉ា	អត្តលេខ ០០០១៨៧
៥-ឧត្តមសេនីយ៍ទោ	ពៅ	ហេង	អត្តលេខ ០០០៩៦១
៦-វរសេនីយ៍ឯក	ប្រាក់	ផាន់ណារ៉ា	អត្តលេខ ០០៣៨០៣

ឃ_គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

១-វរសេនីយ៍ឯក	ផង់	ដារាចន្ទ្រា	អត្តលេខ ០០០៦៨២
២-វរសេនីយ៍ឯក	ទួន	ម៉ារី	អត្តលេខ ០០១០៨៩
៣-វរសេនីយ៍ឯក	ស៊ុ	សុផាន់	អត្តលេខ ០១៣០៣៨
៤-វរសេនីយ៍ឯក	សួន	គឹមសុខ	អត្តលេខ ០០២១១៥
៥-វរសេនីយ៍ឯក	សុឃ	ប្រាក់	អត្តលេខ ០១៧៨២៩
៦-វរសេនីយ៍ឯក	ថៃ	គន្ធ	អត្តលេខ ០១៥៣០៦
៧-វរសេនីយ៍ទោ	ឈុម	ដារ៉ា	អត្តលេខ ០៣០៦៧២
៨-វរសេនីយ៍ទោ	ឌី	ឈុម	អត្តលេខ ០០៩៩៨៨
៩-វរសេនីយ៍ទោ	សុខ	សារ៉ាត់	អត្តលេខ ០០៨៨៩៤
១០-វរសេនីយ៍ទោ	ឡោ	សំអូន	អត្តលេខ ០១៨៨២១
១១-វរសេនីយ៍ទោ	សាន	បញ្ញា	អត្តលេខ ១៨៥៦៨៦
១២-វរសេនីយ៍ទោ	ឈាង	ចាន់ដេត	អត្តលេខ ០៣០៩៧៦

ង_គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១-ឧត្តមសេនីយ៍ត្រី	សោម	សុវណ្ណា	អត្តលេខ ០០៣១៦៧
២-ឧត្តមសេនីយ៍ត្រី	លី	សុវ៉ារិទ្ធ	អត្តលេខ ០០១១៥៤
៣-វរសេនីយ៍ឯក	ហ៊ួ	ចាន់ដារ៉ា	អត្តលេខ ០០៣១៧៦

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៤-វរសេនីយ៍ឯក	គុយ	សិរីវុឌ្ឍី	អត្តលេខ ០០២១០៨
៥-វរសេនីយ៍ឯក	ឈុំ	ចិសោល	អត្តលេខ ០១០៨៦៦
៦-វរសេនីយ៍ឯក	ចាន់	ចិន្តា	អត្តលេខ ០០២៨៥៦
៧-វរសេនីយ៍ឯក	ហួត	ចន្ថា	អត្តលេខ ០០១៤២៨
៨-វរសេនីយ៍ឯក	ប៉ាច	នុត	អត្តលេខ ០០៨៤៣១
៩-វរសេនីយ៍ឯក	ឡុង	ណាម	អត្តលេខ ០០២៨១២
១០-វរសេនីយ៍ទោ	សៀ	សំណាង	អត្តលេខ ០២៦០២០

ច. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

១-វរសេនីយ៍ឯក	ចាឡូ	ម៉ុនឡឿង	អត្តលេខ ០០៤៩៥៣
២-វរសេនីយ៍ឯក	គង់	គីម	អត្តលេខ ០០៩៦៤៤
៣-វរសេនីយ៍ឯក	គុណ	ម៉ង់ឌី	អត្តលេខ ០១២៥៧៤
៤-វរសេនីយ៍ឯក	គង់	សុផល	អត្តលេខ ០០៩០៩៤
៥-វរសេនីយ៍ឯក	អ៊ុក	ណាត្រី	អត្តលេខ ០០៤១៤៨
៦-វរសេនីយ៍ឯក	ជា	សោភ័ណ្ឌា	អត្តលេខ ០០៤១៤៩
៧-វរសេនីយ៍ឯក	អ៊ឹម	ចុស្សា	អត្តលេខ ០០៩១០០
៨-វរសេនីយ៍ទោ	លឹម	គាងគុង	អត្តលេខ ១៩៨៦៧៦
៩-វរសេនីយ៍ទោ	គង់	សោខន	អត្តលេខ ០០៤១៤៤
១០-វរសេនីយ៍ទោ	ជាន	គីមមួន	អត្តលេខ ០០៩០៩០
១១-វរសេនីយ៍ទោ	នុត	ជាណារី	អត្តលេខ ០២៦៥៤២
១២-វរសេនីយ៍ទោ	ហួន	ឡឿន	អត្តលេខ ០១០៥៥៧
១៣-វរសេនីយ៍ទោ	ដួង	ញឹម	អត្តលេខ ០០៩៦០៦
១៤-វរសេនីយ៍ទោ	លី	សុខគ្រី	អត្តលេខ ០៤០១៩១
១៥-វរសេនីយ៍ត្រី	សួន	ស៊ីឡួន	អត្តលេខ ០២៨៩០៣
១៦-វរសេនីយ៍ត្រី	ប្រាក់	ផានិត	អត្តលេខ ០៤៨២០០
១៧-វរសេនីយ៍ត្រី	ជា	សុផា	អត្តលេខ ១០៦៤៧៥

ឆ. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១-ឧត្តមសេនីយ៍ឯក	ឯល	ម៉ាន់សូវ៉ាត់	អត្តលេខ ០០០០៥៤
២-ឧត្តមសេនីយ៍ឯក	ឈឹម	សាខុន	អត្តលេខ ០០១៩៤៨
៣-វរសេនីយ៍ទោ	ម៉ាល	សំណាង	អត្តលេខ ០១០៦៤៥
៤-វរសេនីយ៍ទោ	ជាន	ដារិ	អត្តលេខ ០១០៦៤៥
៥-វរសេនីយ៍ទោ	ជ័យ	សារុន	អត្តលេខ ០១៦០៧៩
៦-វរសេនីយ៍ទោ	ចាន់	សូវ៉ាត់	អត្តលេខ ០២៧៧១៩

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៧-វរសេនីយ៍ត្រី	សួស	អក្ខរា	អត្តលេខ ០១៨៥៧០
៨-វរសេនីយ៍ត្រី	តេត	សុជាតិ	អត្តលេខ ០១៣១២៧
៩-វរសេនីយ៍ត្រី	ជួន	ឈាង	អត្តលេខ ០១៥៨៦៩
១០-វរសេនីយ៍ត្រី	ជូ	ខ្ទួម	អត្តលេខ ០០៩៩៩២
១១-វរសេនីយ៍ត្រី	ទេព	ឈៀក	អត្តលេខ ០០៩៩៩០
១២-វរសេនីយ៍ត្រី	គង់	ស៊ុន	អត្តលេខ ០០៩៩៩៦
១៣-វរសេនីយ៍ត្រី	ម៉ៅ	ឌីណា	អត្តលេខ ០១៩០៧៣
១៤-វរសេនីយ៍ត្រី	អ៊ុង	សារឹម	អត្តលេខ ០១៥៤៦៣
១៥-វរសេនីយ៍ត្រី	អ៊ុក	សំណាង	អត្តលេខ ០១៥៤៦១
១៦-វរសេនីយ៍ត្រី	គឹម	ប្រសើរ	អត្តលេខ ១១២៦៩២

៥-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

១-បណ្ឌិត	ចាន់	សាវ៉ារី	
២-បណ្ឌិត	សេង	ចន្ទារិទ្ធ	
៣-អនុបណ្ឌិត	ចង់	សុផារ៉ា	
៤-អនុបណ្ឌិត	ណុច	សុខា	
៥-អនុបណ្ឌិត	ខ្មៅ	សាមន	
៦-អនុបណ្ឌិត	ទី	ណារឿង	
៧-អនុបណ្ឌិត	ជ័យ	សំអៀង	
៨-អនុបណ្ឌិត	ឈួន	គ្រាយ	
៩-អនុបណ្ឌិត	យឹម	ម៉ុងឿង	
១០-អនុបណ្ឌិត	ទួន	ហ៊ន	
១១-អនុបណ្ឌិត	អ៊ុង	យ៉ែត	
១២-អនុបណ្ឌិត	គុំ	សុរិទ្ធ	
១៣-វរសេនីយ៍ទោ	ហាំ	សុខា	អត្តលេខ ០០៩៨២៣
១៤-វរសេនីយ៍ទោ	ឈឿម	ផៃ	អត្តលេខ ០១៦៨៥៩
១៥-វរសេនីយ៍ទោ	ម៉េង	សុផាត	អត្តលេខ ០២៦៥៣៧
១៦-វរសេនីយ៍ទោ	លឹម	ជី	អត្តលេខ ០៣៥០៣៩
១៧-វរសេនីយ៍ត្រី	ឈាង	សំអុល	អត្តលេខ ០១៧៩២៦
១៨-វរសេនីយ៍ត្រី	សារ៉េត	សុផាត	អត្តលេខ ០០៩០៨៧
១៩-វរសេនីយ៍ត្រី	ហ៊ុយ	ម៉ាំ	អត្តលេខ ០៣៥០៣៦
២០-វរសេនីយ៍ត្រី	ទី	ហង្សន័យ	អត្តលេខ ០៨៦៨០៧
២១-វរសេនីយ៍ត្រី	សុខ	ខាត់ណា	អត្តលេខ ០០៩៦៣៨

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

២២-ពលសេនីយ៍ត្រី	ប៉ាល់	សុផល	អត្តលេខ ០៣៨០៧៧
២៣-ពលសេនីយ៍ត្រី	អ៊ុម	អឿន	អត្តលេខ ០១០៣៧៥
២៤-ពលសេនីយ៍ត្រី	អ៊ូ	សុខឿន	អត្តលេខ ០១១៣៨៩
២៥-ពលសេនីយ៍ត្រី	សុត	សារឿម	អត្តលេខ ០២៧៨០៣
២៦-ពលសេនីយ៍ត្រី	គន្ធ	សុគន្ធា	អត្តលេខ ០១០៣៧៦
២៧-ពលសេនីយ៍ត្រី	ហុក	សាខឿន	អត្តលេខ ០១០៦៧៥
២៨-ពលសេនីយ៍ត្រី	ជួន	ជារា	អត្តលេខ ០១០៦៧៩
២៩-ពលសេនីយ៍ត្រី	សែន	ហាត់	អត្តលេខ ០១៥៨៥៥
៣០-ពលសេនីយ៍ត្រី	គាត់	ម៉ែន	អត្តលេខ ០១០៦៨១
៣១-ពលសេនីយ៍ត្រី	ហ៊ុន	សាម៉េត	អត្តលេខ ០១៥៨៦៨
៣២-ពលសេនីយ៍ត្រី	អ៊ុក	យ៉ឹន	អត្តលេខ ០១៨៦៥៥
៣៣-ពលសេនីយ៍ត្រី	ផាត	សុវៃ	អត្តលេខ ០៩១០៧៥
៣៤-ពលសេនីយ៍ត្រី	ម៉ុក	សុចន្ធារ៉ា	អត្តលេខ ០០៩៨៣០
៣៥-ពលសេនីយ៍ត្រី	ជួន	ស	អត្តលេខ ០០៩៨២៨
៣៦-ពលសេនីយ៍ត្រី	ជា	ឧត្តី	អត្តលេខ ០០៩៧៣៦
៣៧-ពលសេនីយ៍ត្រី	ជួន	ឧត្តី	អត្តលេខ ០២៨០៧៧
៣៨-ពលសេនីយ៍ត្រី	មិត	សារិទ្ធ	អត្តលេខ ០០៩៧៣៧

ព្រះហស្តលេខា និងព្រះរាជលញ្ជករ

នរោត្តម សីហមុនី

លេខៈ ៤៩៨ ប.ល

ដើម្បីចម្លងចេញ

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១២

អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកអគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

៣៧៣-១២០៦-៥២៩

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានដំឡើងឋានៈឯកឧត្តម **ពេជ សារឿន** ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរកៈ ១៤០៦-៥៣០

លេខៈ ៥០៦ ច.ល
ជម្រាបជូនចេញ
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ២០១២
អគ្គលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី
សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២

p

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៤៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **សុខ ចាន់នី** ឱ្យបំពេញមុខងារជានាយកខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក។

មាត្រា ២: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៣៧-១៤០៦-៥៣១

លេខ: ៥៤៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ... ខែ... ឆ្នាំ២០១២
...ទីស្តីការគណៈរដ្ឋមន្ត្រី
...សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២

p

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៤៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **សុខ សុភាន** ឱ្យបំពេញមុខងារជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

មាត្រា ២: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៣៧-១៤០៦-៥៣៤

លេខ: ៥៩០ ច.ល
[illegible]
រាជធានីភ្នំពេញ [illegible] ខែ មិថុនា ឆ្នាំ២០១២
[illegible] រាជរដ្ឋាភិបាល
[illegible] សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២

p

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម អស់លោក លោកស្រី មន្ត្រីរាជការនៅខេត្តបន្ទាយមានជ័យចំនួន ២៧ រូប ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចបានល្អប្រសើរ មានស្មារតីទទួលខុសត្រូវខ្ពស់ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

ឲ្យ

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

-ឯកឧត្តម **ប៉ុក សារុយ**

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

១-ឯកឧត្តម **ជង់ ប្រសើដ្ឋ**
២-លោកស្រី **គល ចន្ទ**
៣-លោក **ម៉ៅ សួរ**
៤-លោក **ហេង ប៊ុនហោ**
៥-លោកស្រី **ព្រំ ស៊ីណា**
៦-លោក **ព្រឹម សារី**
៧-លោកស្រី **ឈឹម កញ្ញា**

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មិត្តមិត្ត**

១-លោក **ចៅ ម៉េងជួង**
២-លោក **សេង ភ**
៣-លោក **ពៅ សំណាង**
៤-លោក **យិន យឿង**
៥-លោក **យុន ឆុន្នី**
៦-លោក **ឈឹម សុខេត**
៧-លោកវេជ្ជ. **កែច សុភ័ក្ត្រា**
៨-លោក **ឈើយ ចាន់ណា**
៩-លោក **ស៊ុម សារឿន**
១០-លោក **ពុធ សុភ័គ**
១១-លោក **ឈឹម លី**
១២-លោក **អ៊ុង អ៊ុម**
១៣-លោក **ថៃ គេចលី**

ROYAUME DU CAMBODGE · LE MINISTRE ... ROYAL

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១-លោក **វង្ស សុខា** ៣-លោក **គង់ ជាវ៉ា**

២-លោក **ទៅ ឆុត**

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

១-លោកស្រី **អៀង កណ្ណារ៉ា** ៣-លោក **ឈាង ឆុង្វី**

២-លោក **ហុង ប្រកប**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត.០៦១២.៥៣៣

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១២

លេខ: ៤៩១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១២

[illegible]រាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តមថ្នាក់ដឹកនាំក្រុងកិនធឺ និងខេត្តហ៊ូវយ៉ាង នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ជាខេត្តសម្ព័ន្ធមេត្រីភាព ជាមួយខេត្តកំពង់ឆ្នាំង នៃព្រះរាជាណាចក្រកម្ពុជា ដែលបានជួយកសាងសមិទ្ធិផលជាច្រើនសម្រាប់ប្រជាជនខេត្តកំពង់ឆ្នាំង ពិសេសបានសាងសង់ស្តូបបូជនីយកិច្ចមិត្តភាពកម្ពុជា វៀតណាមឡើងវិញបានរួចជាស្ថាពរ ។

នូវ

គ្រឿងឥស្សរិយយស **មហាសេរីវឌ្ឍន៍** ថ្នាក់ **មហាសេនា**

១-ឯកឧត្តម **ត្រាន ថាញ់ម៉ាន** TRAN THANH MAN

២-ឯកឧត្តម **វិន មិនចាក** VINH MINH CHAC

ភភរ.១៤០៦.៥៣៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ៥០៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២
ផ្នុលេខាធិការដ្ឋានទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាល
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៤៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ព្រះសង្ឃ ចំនួន០៤អង្គ ជាព្រះចៅអធិការវត្ត មានគុណបំណាច់ចំពោះជាតិនិងសាសនា ដោយបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមកសាងសមិទ្ធផលនានាជាច្រើនដើម្បីលើកស្ទួយវិស័យព្រះពុទ្ធសាសនា ស្ថិតនៅក្នុងវត្តកោះអាជីវង្ស វត្តបទុមវតី វត្តព្រៃល្វា វត្តសាមគ្គីធម្មារាមកែមខ្លួន និងវត្តសាមគ្គីរាជវរារាម រាជធានីភ្នំពេញ សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១-ព្រះទេវសត្ថា ពៀយ មេត្តា
២-ព្រះសទ្ធម្មញាណ ឈុន សុចិន
៣-ព្រះលក្ខណ៍មុនី សួង សោចិន
៤-ព្រះសង្ឃមុនី មួង ចក្រី

៣៧-១២០៦-៥៣៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៥១០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០[illegible] ខែ [illegible] ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៣០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ជូន

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឯកឧត្តម សៀង លួនឡឺ

មានគុណបំណាច់ និងស្នាដៃល្អ

ក្នុងការចូលរួមជួយកសាង និងអភិវឌ្ឍន៍ភូមិឃុំ មួយចំនួនក្នុងស្រុកទ្រាំង ខេត្តតាកែវ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.១២០៦-៥៣៦

លេខៈ ៤៨៥ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible] រាជរដ្ឋាភិបាល
[illegible] សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២

p

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៣១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ព្រះរាជទាន

ដូច

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

ចំពោះ

លោកជំទាវ ឆេត សារិន និង សំនាង

ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួន
ចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅស្រុកជុំគិរី ខេត្តកំពត

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧-១៤០៦-៥៣៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២

លេខ: ៥១១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ [illegible] ខែមិថុនា ឆ្នាំ២០១២
[illegible] រាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/ រកត/០៩០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **វ៉ាង ហៅ** អត្តលេខ ១២៦៤៤ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧-១៤០៦-៥៣៧

បានយកសេចក្តីចម្លងត្រឹមត្រូវ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១២
រដ្ឋលេខាធិការទទួលបន្ទុករដ្ឋាភិបាល
សយ សុខា

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១២

p

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៣៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃវុឌ្ឍសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៤ នៃវុឌ្ឍសភា នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំវុឌ្ឍសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងលោកជំទាវ យួន សុដារី ជាអនុប្រធានទី២ នៃវុឌ្ឍសភា នីតិកាលទី៤ នៅក្នុងសម័យប្រជុំពេញអង្គវុឌ្ឍសភា លើកទី៨ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២
- បានទ្រង់យល់ច្បាប់ស្តីពីថវិកាប្រចាំឆ្នាំ ២០១២ របស់វុឌ្ឍសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានវុឌ្ឍសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១.- ត្រូវបានតែងតាំងឯកឧត្តម លោកជំទាវ ជាទីប្រឹក្សា និងជំនួយការ លោកជំទាវ **យួន សុដារី** អនុប្រធានទី២ នៃវុឌ្ឍសភា ដែលមានសមាសភាពដូចខាងក្រោម៖

ក- ទីប្រឹក្សា

១- លោកជំទាវ **ឈិត្យ ម៉ាំងដារា** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២- លោកជំទាវ **ដូ ញ** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៣- ឯកឧត្តម **កុសល ខេមរិទ្ធ** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៤- ឯកឧត្តម **មិត្ត ធីមាន** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

ខ-ជំនួយការ

១- លោកជំទាវ **រ៉េន សុខឡេងា** មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

មាត្រា២ .. សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ .. ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត/០៦១២/៥៣៩

លេខ: ៤៩៧ ច.ល

ដើម្បីចម្លងចែកជូន

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១២

[illegible] ជាតិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១២

[illegible] សុខា

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.១២៩ ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តព្រះវិហារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

p

សម្រេច

មាត្រា១:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដី ទំហំ ៩.១២៩ (ប្រាំបួនពាន់មួយរយម្ភៃប្រាំបួន) ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះវិហារ ក្រោមល័ក្ខខ័ណ្ឌសម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិកម្ម និងដំណាំកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១៨៥ សជណាចុះថ្ងៃទី១៧ ខែ កុម្ភៈ ឆ្នាំ២០១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

មាត្រា៣:

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៤:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៤
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១.៩៦៥ ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តឧត្តរមានជ័យ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែ ឧសភាឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ១.៨៦៥ (មួយពាន់ប្រាំបីរយហុកសិបប្រាំ) ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ ក្រោមល័ក្ខខ័ណ្ឌសម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ២០៥ សជណ.កស ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

មាត្រា៣:

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៤:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៤
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :[illegible]-បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១.១៩៥ ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តឧត្តរមានជ័យ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ២០០៨ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បកចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

p

សម្រេច

មាត្រា១:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ១.១៩៥ (មួយពាន់មួយរយកៅសិបប្រាំ) ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ ក្រោមល័ក្ខខ័ណ្ឌសម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ២០៤ សជណ.កស ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា២:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

មាត្រា៣:

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៤:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តខេត្តឧត្តរមានជ័យត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៩៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.៤៧៧ ហិកតាក្នុងតំបន់ជម្រកសត្វព្រៃភ្នំណាមលៀរ ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តមណ្ឌលគិរី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ខែ ឧសភា ឆ្នាំ ២០០៨ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៩.៤៧៧ (ប្រាំបួនពាន់បួនរយចិតសិប ប្រាំពីរ) ហិកតាក្នុងតំបន់ជម្រកសត្វព្រៃភ្នំណាមលៀរ ស្ថិតក្នុងភូមិសាស្រ្តខេត្តមណ្ឌលគិរី ក្រោមល័ក្ខខ័ណ្ឌ សម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១៨៦សជណ ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១២ របស់ទីស្តីការគណៈរដ្ឋ មន្រ្តី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែង នីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរ ដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

មាត្រា៣:

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤:

រដ្ឋមន្រ្តីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង បរិស្ថាន គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៤.០៩៥ ហិកតាក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ខែ ឧសភា ឆ្នាំ ២០០៨ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

p

សម្រេច

មាត្រា១:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៤.០៩៥ (បួនពាន់កៅសិបប្រាំ) ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ ក្រោមល័ក្ខខ័ណ្ឌសម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ២៤៩ សជណ ចុះថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១២ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

មាត្រា៣:

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១២

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

__កន្លែងទទួល:__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.៧០០ ហិកតាក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ខែ ឧសភា ឆ្នាំ ២០០៨ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ៩.៧០០(ប្រាំបួនពាន់ប្រាំពីររយ)ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ ក្រោមល័ក្ខខ័ណ្ឌសម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទីនិងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ៣៧១ សជណ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១២ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

មាត្រា៣:

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១២

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៨. អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញឈើធំនិញមួយចំនួន

រាជរដ្ឋាភិបាល

- *បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*
- *បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា*
- *បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី*
- *បានឃើញព្រះរាជក្រមលេខ ០១. នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១.នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៩*
- *បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥*
- *បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ*
- *បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគយ*
- *បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២១ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០*

- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ១៧៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ២៦៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- បានឃើញពិធីសារស្តីពីការអនុវត្តនាមវលីនៃតារាងពន្ធគយស៊ីចង្វាក់របស់អាស៊ាន (AHTN) ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៣ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

មាត្រា ១.-

ត្រូវបានកែសម្រួលអត្រាអាករពិសេសពី ៥% ទៅ ១០% លើមុខទំនិញចំនួន ០៣ បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជា ដែលស៊ីចង្វាក់ជាមួយនាមវលីនៃតារាងពន្ធគយស៊ីចង្វាក់របស់អាស៊ាន ២០១២ (AHTN 2012) ជាធរមាន ក្នុងទីតាំងរងលេខ ៨៧១១.២០.២០ ៨៧១១.២០.៣៩ និង ៨៧១១.២០.៥៩។

មាត្រា ២.-

ត្រូវបានកែសម្រួលអត្រាអាករនាំចេញពី ០% ទៅ ១០% លើមុខទំនិញចំនួន ៣១ បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជា ដែលស៊ីចង្វាក់ជាមួយនាមវលីនៃតារាងពន្ធគយស៊ីចង្វាក់របស់អាស៊ាន ២០១២ (AHTN 2012) ជាធរមាន ក្នុងទីតាំងរងលេខ ៖

០៣០៥.៧២.១០	០៣០៦.១១.០០	០៣០៦.១២.០០	០៣០៦.១៤.១០	០៣០៦.១៤.៩០
០៣០៦.១៥.០០	០៣០៦.១៦.០០	០៣០៦.១៧.១០	០៣០៦.១៧.២០	០៣០៦.១៧.៣០
០៣០៦.១៧.៩០	០៣០៦.១៩.០០	០៣០៦.២១.៩១	០៣០៦.២១.៩៩	០៣០៦.២២.៩១
០៣០៦.២២.៩៩	០៣០៦.២៤.៩១	០៣០៦.២៤.៩៩	០៣០៦.២៥.០០	០៣០៦.២៦.៩១
០៣០៦.២៦.៩៩	០៣០៦.២៧.៩១	០៣០៦.២៧.៩៩	០៣០៦.២៩.៩១	០៣០៦.២៩.៩៩
០៣០៧.២៩.២០	០៣០៧.៣៩.២០	០៣០៧.៦០.៣០	០៣០៧.៧៩.២០	០៣០៧.៨៩.២០

និងទីតាំងរងលេខ ០៣០៧.៩៩.២០ ។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកចាត់ចែងអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១២ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជំរាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ចម្លងជូន ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់សាលាខេត្ត និងសាលារាជធានី
- ដូចមាត្រា ៤
- រាជកិច្ច

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៥៥.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសហមេត្រី តាមលំដាប់ថ្នាក់ ជូនអង្គភាពបញ្ជាការយោធា និងនគរបាល ខេត្តយ៉ាឡាយ និងខេត្តកុនទុម នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចំនួន ០៥អង្គភាព ដែលមានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការមិត្តភាព រវាងកម្ពុជា និងវៀតណាម ដូចមានរាយនាមខាងក្រោម៖

ក-មេដាយសហមេត្រី ថ្នាក់ សេនា

- **គណៈបញ្ជាការយោធាភូមិភាគទី៥**

ខ-មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ

១- **គណៈបញ្ជាការយោធាខេត្តយ៉ាឡាយ**

២- **គណៈបញ្ជាការនគរបាលខេត្តយ៉ាឡាយ**

៣- **គណៈបញ្ជាការយោធាខេត្តកុនទុម**

៤- **គណៈបញ្ជាការនគរបាលខេត្តកុនទុម**

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ មិថុនា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៥៦ .អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ** ចំនួន ០១គ្រឿង ជូនលោក MASAHIRO SANO ប្រធានអង្គការក្រៅរដ្ឋាភិបាលកុគីសៃ KJO ដែលបានរួមចំណែកក្នុងការផ្តល់អំណោយជាកង់ ដល់មណ្ឌលកុមារកំព្រានានា ចំនួន ០៦លើក ដូចជា មណ្ឌលកុមារកំព្រា ទួលស្លែង ខេត្តកំពត ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម ហើយលើកទី៦ នៅមណ្ឌលកុមារកំព្រា ខេត្តសៀមរាប។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៥៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០៤គ្រឿង ជូនបុគ្គលិកអង្គការអាស៊ីអាស្តេកាប្រចាំកម្ពុជា ដែលបានរួមចំណែកក្នុងការផ្តល់អំណោយជាកង់ ដល់មណ្ឌលកុមារកំព្រានានា ចំនួន ០៦លើក ដូចជា មណ្ឌលកុមារកំព្រាទួលស្លែង ខេត្តកំពត ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម ហើយលើកទី៦ នៅមណ្ឌលកុមារកំព្រា ខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម៖

១-	លោក	MASATAKA SUZUKI	ប្រធានមូលនិធិមជ្ឈមណ្ឌលរៀបចំចំណតកង់
២-	លោក	KIYOHISA SUZUKI	ប្រធាន SHINFUJI Rotaryclub
៣-	លោក	TOSHIAKI HAKAMATA	ប្រធាន HAMAMAT SUNISHI Rotaryclub
៤-	លោក	SHUICHI YAMAOKA	ប្រធាន International Service Committees

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៥៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតម្លើងថ្នាក់តាមសញ្ញាបត្រជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដំឡើងថ្នាក់តាមសញ្ញាបត្រក្នុងឋានន្តរស័ក្តិ វរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ចំនួន ០៨ រូប មាននាមដូចខាងក្រោម :

ល.រ	គោត្តនាម និងនាម	ភេទ	ឋានន្តរស័ក្តិ ថ្នាក់ចាស់	ឋានន្តរស័ក្តិ ថ្នាក់ថ្មី
១	សួស ប្រាថ្នា	ប្រុស	ពី វរមន្ត្រី ថ្នាក់លេខ ៨	ទៅជា វរមន្ត្រី ថ្នាក់លេខ ៧
២	ម៉ុត សារ៉េត	ប្រុស	ពី វរមន្ត្រី ថ្នាក់លេខ ៩	ទៅជា វរមន្ត្រី ថ្នាក់លេខ ៨
៣	ហួត ហៃ	ប្រុស	ពី វរមន្ត្រី ថ្នាក់លេខ ៩	ទៅជា វរមន្ត្រី ថ្នាក់លេខ ៨
៤	អ៊ឹម លាង	ប្រុស	ពី វរមន្ត្រី ថ្នាក់លេខ ១០	ទៅជា វរមន្ត្រី ថ្នាក់លេខ ៩
៥	ញ៉ី ហួង	ប្រុស	ពី វរមន្ត្រី ថ្នាក់លេខ ១០	ទៅជា វរមន្ត្រី ថ្នាក់លេខ ៩
៦	ម៉ុន នេង	ប្រុស	ពី វរមន្ត្រី ថ្នាក់លេខ ១០	ទៅជា វរមន្ត្រី ថ្នាក់លេខ ៩
៧	ស៊ូ អេក៉ហ្វាត់	ប្រុស	ពី វរមន្ត្រី ថ្នាក់លេខ ១០	ទៅជា វរមន្ត្រី ថ្នាក់លេខ ៩
៨	ប្រាក់ សំអឿន	ប្រុស	ពី វរមន្ត្រី ថ្នាក់លេខ ១០	ទៅជា វរមន្ត្រី ថ្នាក់លេខ ៩

p

មាត្រា ២ : បៀវត្សមូលដ្ឋានរបស់ សាមីខ្លួន ត្រូវបានអនុវត្តគិតចាប់ពីថ្ងៃចេញអនុក្រឹត្យនេះ ដោយរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាពឲ្យនៅដដែល ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុង មាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"
- ដូចមាត្រា ១ និងមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៥៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដំឡើងឋានន្តរស័ក្តិ និងតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីសហលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែ មករា ឆ្នាំ២០០៨ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៩១៥ អនក្រ.តត ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១១ ស្តីពីការកែសម្រួលចំនួនគណៈអភិបាលខេត្ត
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិ និងតែងតាំងមន្ត្រីរាជការចំនួន ០២រូប ជាអភិបាលរង នៃគណៈអភិបាលខេត្តក្រចេះ ដូចមានរាយនាមខាងក្រោម :

១- លោក **ខំណុ ចំណាន** ពីឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៩ ទៅជាឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ១០ និងតែងតាំងជាអភិបាលរង នៃគណៈអភិបាលខេត្តក្រចេះ

២- លោក **ចាវ ជុន** ពីឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៩ ទៅជាឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ១០ និងតែងតាំងជាអភិបាលរង នៃគណៈអភិបាលខេត្តក្រចេះ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧០-អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេនព្រះតេជគុណ**មាស ឌុច** ព្រះចៅអធិការវត្តខ្សាច់ល្អិត ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកក្នុងការកសាងសមិទ្ធផលនានា ដើម្បីលើកស្ទួយវិស័យព្រះពុទ្ធសាសនា មានព្រះវិហារ កុដិ សាលាឆាន់ សាលាបុណ្យ សាលាបាលី របង ខ្លោងទ្វារ ធ្វើផ្លូវ និងចាក់ដីក្នុងវត្ត ស្ថិតនៅក្នុងវត្តខ្សាច់ល្អិត ឃុំចុងដូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ចំណាយអស់បច្ច័យចំនួន ៦៣.៥២២ ដុល្លារអាមេរិក ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈ អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
 អគ្គលេខាធិការដ្ឋានរដ្ឋសភា
 អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៦៦១...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន២៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកក្នុងការកសាងសមិទ្ធផលនានា ដើម្បីលើកស្ទួយវិស័យព្រះពុទ្ធសាសនា មានព្រះវិហារ កុដិ សាលាឆាន់ សាលាបុណ្យ សាលាបាលី របង ខ្លោងទ្វារ ធ្វើផ្លូវ និងចាក់ដីក្នុងវត្តស្ថិតនៅក្នុងវត្តខ្សាច់ល្អិត ឃុំចុងដូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិ:

១-ឯកឧត្តម	ហោ	សារុន	សប្បុរសជន	ថវិកាចំនួន ១១.៦៧៨ ដុល្លារ
២-អ្នកស្រី	សូ	ឈឹម	សប្បុរសជន	ថវិកាចំនួន ១០.៨៧៤ ដុល្លារ
៣-អ្នកស្រី	ខូច	គ្រុយ	សប្បុរសជន	ថវិកាចំនួន ១០.៧១៣ ដុល្លារ
៤-អ្នកស្រី	នី	ឡោ	សប្បុរសជន	ថវិកាចំនួន ១០.៦៦២ ដុល្លារ
៥-លោក	ម៉ិល	ពឿន	សប្បុរសជន	ថវិកាចំនួន ១០.៥២៥ ដុល្លារ
៦-លោក	ខៀវ	ធឿន	សប្បុរសជន	ថវិកាចំនួន ១០.៤២៤ ដុល្លារ
៧-លោក	ឃុត	ធុយ	សប្បុរសជន	ថវិកាចំនួន ១០.៣៦៧ ដុល្លារ
៨-អ្នកស្រី	ង	ស៊ិត	សប្បុរសជន	ថវិកាចំនួន ១០.២៥២ ដុល្លារ
៩-អ្នកស្រី	គន	គុំ	សប្បុរសជន	ថវិកាចំនួន ១០.២១៤ ដុល្លារ
១០-លោក	ទិម	រុន	សប្បុរសជន	ថវិកាចំនួន ១០.០៩៥ ដុល្លារ

p

១១-លោក	ពីង	សុខជា	សប្បុរសជន	ថវិកាចំនួន ១០.០៧៣ ដុល្លារ
១២-លោក	ជា	ផល	សប្បុរសជន	ថវិកាចំនួន ១០.០២៥ ដុល្លារ
១៣-អ្នកស្រី	សុខ	ខុម	សប្បុរសជន	ថវិកាចំនួន ១០.០១៣ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ:

១-លោក	គឿន	គោ	សប្បុរសជន	ថវិកាចំនួន ៥.៨២៣ ដុល្លារ
២-លោក	សឹង	ស៊ី	សប្បុរសជន	ថវិកាចំនួន ៥.៧១៤ ដុល្លារ
៣-អ្នកស្រី	គី	ទ៊ាន់ជន	សប្បុរសជន	ថវិកាចំនួន ៥.៦២៦ ដុល្លារ
៤-លោក	គីម	ឃិន	សប្បុរសជន	ថវិកាចំនួន ៥.៥៩៤ ដុល្លារ
៥-អ្នកស្រី	ហាស	រ៉ុន	សប្បុរសជន	ថវិកាចំនួន ៥.៤២២ ដុល្លារ
៦-លោក	ថេង	ម៉ារិទ្ធ	សប្បុរសជន	ថវិកាចំនួន ៥.៣១៥ ដុល្លារ
៧-អ្នកស្រី	សាន	សឿន	សប្បុរសជន	ថវិកាចំនួន ៥.២១៨ ដុល្លារ
៨-អ្នកស្រី	គី	ប៊ុយ	សប្បុរសជន	ថវិកាចំនួន ៥.២១០ ដុល្លារ
៩-លោក	រស់	ស្រេង	សប្បុរសជន	ថវិកាចំនួន ៥.១៩៥ ដុល្លារ
១០-អ្នកស្រី	ខូច	ស៊ីន	សប្បុរសជន	ថវិកាចំនួន ៥.១២៤ ដុល្លារ
១១-លោក	ឈឹម	អឿន	សប្បុរសជន	ថវិកាចំនួន ៥.០១៣ ដុល្លារ
១២-លោក	សូ	ឃឹម	សប្បុរសជន	ថវិកាចំនួន ៥.០១០ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈ អភិបាលខេត្ត កំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

[illegible] នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៨២.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/០២/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/០៦/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៨/១៧២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានចំណុះលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម
- យោងតាមសំណើររបស់ប្រធានគណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម

សម្រេច

មាត្រា១: ត្រូវបានតែងតាំង ប្រធាននាយកដ្ឋាន នៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងភេរវកម្មចំនួន ៣រូប ដូចមានរាយនាមខាងក្រោម៖

១. លោក ញ៉ែម សុផៃឡា ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

២. លោក បេង គង់ ប្រធាននាយកដ្ឋានចារកម្ម និងស៊ើបអង្កេត

៣. លោក ប៊ុល ច័ន្ទវីរៈ ប្រធាននាយកដ្ឋានពត៌មានវិទ្យា។

p

មាត្រា២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាម៉ីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ខែ មិថុនា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៦៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងអគ្គលេខាធិការរង
នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់-ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីវិសោធនកម្ម មាត្រា ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១១/៩៨១ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១ ស្តីពីវិសោធនកម្មមាត្រា ១ នៃព្រះរាជក្រឹត្យលេខ សន/រកត/១០០៨/១១០៦ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីវិសោធនកម្មមាត្រា ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិសោះស្រាយទំនាស់ដីធ្លី

p

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-បានឃើញអនុក្រឹត្យលេខ ១២២៧ អនក្រ.តត ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ស្តីពីការកែសម្រួលសមាសភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំង ឯកឧត្តម **ហ៊ុន ម៉ានិត** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី បន្ថែមលើមុខងារបច្ចុប្បន្ន។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៦៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យ លេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យ លេខ ៥២ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យ លេខ ១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៤ ស្តីពីការផ្ទេររដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ឲ្យស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

សម្រេច

មាត្រា ១: ត្រូវបានតែងតាំងលោក **ស៊ឹម ស៊ីថា** ជាអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១២ ។

មាត្រា ២: បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ... ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៦៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្ត ការផ្លាស់ប្តូរក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោកស្រី **នខ ឆ្នូត** ឲ្យបំពេញមុខងារជាអគ្គនាយករងទូរទស្សន៍ជាតិកម្ពុជានៃក្រសួងព័ត៌មាន ជំនួសលោកស្រី ចំនួ ធី ដែលបានចូលនិវត្តន៍ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៧៧. អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ** ចំនួន ០៥គ្រឿង ជូនមន្ត្រីនគរបាល និងយោធា ចំនួន ០៥រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមកសាង អភិវឌ្ឍន៍ប្រទេសជាតិ នាពេលកន្លងមក ដូចមានរាយនាមខាងក្រោម៖

១-វរសេនីយ៍ទោ **ជុន ថារិទ្ធ** អត្តលេខ ០៨៩៤៥ អនុប្រធានការិយាល័យកណ្តាលសណ្តាប់ធ្នាប់ ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង

២-វរសេនីយ៍ទោ **ប៊ុល ទុទ្ធី** អត្តលេខ ០២៣២២ អនុប្រធានការិយាល័យព្រហ្មទណ្ឌកម្រិតស្រាល ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង

៣-វរសេនីយ៍ត្រី **ជាង សុវណ្ណារិទ្ធ** អត្តលេខ ១៣៩៧២ អធិការស្រុកបរិបូរណ៍ ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង

៤-អនុសេនីយ៍ឯក **គុយ សេងហៀង** អត្តលេខ ០៣៦៧២៩ គ្រូបង្ហាត់របៀបសាលាពលទាហ៊ាន យោធភូមិភាគពិសេស

៥-អនុសេនីយ៍ទោ **ព្រហ្ម ចន្ថនី** អត្តលេខ ៦៨១២១ នាយរងផ្នែកនីតិវិធី ការិ.ចរាចរណ៍ផ្លូវទឹក នាយកដ្ឋានសណ្តាប់ធ្នាប់

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៦០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ០៩គ្រឿង ជូនសប្បុរសជន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមកសាង និងអភិវឌ្ឍន៍ ប្រទេសជាតិ ទាំងផ្នែកពុទ្ធចក្រ និង អាណាចក្រ ដូចមាននាមខាងក្រោម៖

ក-មេដាយមាសស្ថាបនាជាតិ

-លោក **សុខ ម៉ៅ** សប្បុរសជនរាជធានីភ្នំពេញ ថវិកា ១០.០០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ

១-ឯកឧត្តមឧកញ៉ា **ខេង ចំន្ថា** ទីប្រឹក្សាសម្តេច ហេង សំរិន ប្រធានរដ្ឋសភា ថវិកា ៥.០០០ ដុល្លារ

២-លោកជំទាវ **ឈាង ឆវីចន្ទី** សប្បុរសជនរាជធានីភ្នំពេញ ថវិកា ៥.០០០ ដុល្លារ

៣-លោក **ទឿង ប្រយុទ្ធ** សមាជិកក្រុមការងារចុះជួយស្រុកពញាក្រែក ខេត្តកំពង់ចាម ថវិកា ៥.០០០ ដុល្លារ

៤-លោកស្រី **ទឿង ចាន់ណា** សប្បុរសជនរាជធានីភ្នំពេញ ថវិកា ៥.០០០ ដុល្លារ

គ-មេដាយសំរិទ្ធស្ថាបនាជាតិ

១-ឯកឧត្តម **ឆៃ ម៉េងហុក** ទីប្រឹក្សាសម្តេច ហេង សំរិន ប្រធានរដ្ឋសភា ថវិកា ៣.០០០ ដុល្លារ

២-ឯកឧត្តម **សាន គេង** ទីប្រឹក្សាសម្តេច ហេង សំរិន ប្រធានរដ្ឋសភា ថវិកា ៣.០០០ ដុល្លារ

៣-ឯកឧត្តម **នុន ភក្តី** ទីប្រឹក្សាសម្តេច ហេង សំរិន ប្រធានរដ្ឋសភា ថវិកា ២.៥០០ ដុល្លារ

៤-លោក **អន ភក្តី** មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា ថវិកា ២.៥០០ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៦៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំនួន ២៧គ្រឿង ប្រគេនព្រះសង្ឃ មន្ត្រីរាជការ និង សប្បុរសជន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមកសាង និងអភិវឌ្ឍន៍ ប្រទេសជាតិ ទាំងផ្នែកពុទ្ធចក្រ និង អាណាចក្រ ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ

១-វរសេនីយ៍ត្រី ផុន សុផល អត្តលេខ ០៣៥៣៨៨ ជំនួយការការិយាល័យហិរញ្ញវត្ថុ យោធភូមិភាគទី៥
២-អនុសេនីយ៍ឯក ឆុង តូរ៉ាន់ អត្តលេខ ១៤៧១២ អធិការរងស្រុកឆ្លូង ខេត្តក្រចេះ
៣-អនុសេនីយ៍ឯក សុខ គារដ្ឋ អត្តលេខ ៣៤៤៥០១ ជំនួយការស៊ើបការណ៍ការិយាល័យទី២ កងពលលេខ៦ យោធភូមិភាគទី៥
៤-អនុសេនីយ៍ត្រី សុខ សុវណ្ណា អត្តលេខ ៦៥២៣០ នាយរងប៉ុស្តិ៍ដើមមៀន ស្នងការដ្ឋាននគរបាលខេត្តកណ្តាល
៥-អនុសេនីយ៍ត្រី មាន បុណ្ណារិទ្ធ អត្តលេខ ៧១៨៥៦ មន្ត្រីអគ្គស្នងការដ្ឋាននគរបាលជាតិ
៦-លោក អៀង សុខឃីម ចៅសង្កាត់អូឫស្សីទី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា

១-ព្រះឃោសធម្ម ញៀម សុគន្ធ រាជាគណៈថ្នាក់ទោ ព្រះអនុគណខេត្តកណ្តាល ព្រះចៅអធិការវត្តក្រពើហា ថវិកា ៤០.២៥០ដុល្លា
២-ឯកឧត្តម ជួន ចេវ៉ាទ៍ត ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភាថវិកា ៣០.២៥០ដុល្លា
៣-លោក សុខ សុហោម៉ា សមាជិកក្រុមការងារចុះជួយស្រុកពញាក្រែក ខេត្តកំពង់ចាម
៤-លោក ពេជ្រ លី សមាជិកក្រុមការងារចុះជួយស្រុកពញាក្រែក ខេត្តកំពង់ចាម
៥-វរសេនីយ៍ត្រី នុត ឈឿម អត្តលេខ ០២៨២៧៣ មេបញ្ជាការរង វរសេនាតូចការពារ ព្រំដែនលេខ ១០៣ ខេត្តមណ្ឌលគីរី
៦-លោក ឈឹម នេត្រ សមាជិកក្រុមប្រឹក្សាសង្កាត់បឹងកក់ទី២

p

គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ

១-ឯកឧត្តមបណ្ឌិត ជា ចំរើន	ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាពញាចក្រីហេង សំរិន ប្រធានរដ្ឋសភា ថវិកា ៣០.២៥០ដុល្លា
២-លោក ឡុង ទិបុល	សមាជិកក្រុមការងារចុះជួយស្រុកពញាក្រែក ខេត្តកំពង់ចាម ថវិកា២០.២៥០ដុល្លា
៣-ឯកឧត្តម ពត ចាន់នី	សមាជិកក្រុមការងារចុះជួយ ខេត្តកំពង់ចាម ថវិកា២០.២៥០ដុល្លា
៤-លោក ម៉ៅ សុផល	សប្បុរសជនរាជធានីភ្នំពេញ ថវិកា១០.១០០ដុល្លា
៥-លោក ឡាំ សុខខេម៉ូ	បុគ្គលិកមណ្ឌលសុខភាពខ្សាច់ ស្រុកឆ្លូង ខេត្តក្រចេះ
៦-លោក សេង ហួន	សប្បុរសជនស្រុកឆ្លូង ខេត្តក្រចេះ
៧-អនុសេនីយ៍ត្រី ម៉ុត គំសត់	អត្តលេខ ១៣០៧១៣ ជំនួយការដឹកជញ្ជូន យោធភូមិភាគទី៥
៨-លោកស្រី ជុំយ សុខខេង	សប្បុរសជនស្រុកឆ្លូង ខេត្តក្រចេះ
៩-លោក សោម សុគន្ធារ៉ា	សមាជិកក្រុមការងារចុះជួយស្រុកពញាក្រែក ខេត្តកំពង់ចាម
១០-លោក នុត សោភ័ណ	សមាជិកក្រុមការងារចុះជួយស្រុកពញាក្រែក ខេត្តកំពង់ចាម
១១-លោក ម៉ៅ ចាន់ណា	សមាជិកក្រុមការងារចុះជួយស្រុកពញាក្រែក ខេត្តកំពង់ចាម

១២-លោកវរសេនីយ៍ត្រី យោ ចន្ណះ អត្តលេខ ៣៣២១៣ មន្ត្រីនាយកដ្ឋានអង្គរក្ស នៃក្រសួងមហាផ្ទៃ

១៣-លោកព្រិន្ទបាលទោ គាន់ ម៉េងហុង អត្តលេខ ៦៣៤៣៩ មន្ត្រីនាយកដ្ឋានអង្គរក្ស នៃក្រសួងមហាផ្ទៃ

១៤-លោក ផន អូន	សមាជិកក្រុមការងារចុះជួយស្រុកពញាក្រែក ខេត្តកំពង់ចាម
១៥-អ្នកស្រី អ៊ុំ ចាន់ថន	សប្បុរសជនៅខេត្តសៀមរាប

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៦៩ . អនក្រ . បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរវជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ចំនួន ៦០គ្រឿង ជូនមន្ត្រីរាជការ ដែលមានស្នាដៃល្អ ក្នុងការចូលរួមកសាង និងអភិវឌ្ឍន៍ ប្រទេសជាតិ ទាំងផ្នែកពុទ្ធចក្រ និង អាណាចក្រ ដូចមានរាយនាមខាងក្រោម៖

ក-មេដាយមាសការងារ

០១-ឯកឧត្តម **ឡេង ស្រេង**	ទីប្រឹក្សាក្រសួងអប់រំ យុវជន និងកីឡា
០២-វរសេនីយ៍ឯក **ដួង គីមវណ្ណៈ**	អត្តលេខ ០០២១៨៥ នាយការិយាល័យហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
០៣-វរសេនីយ៍ទោ **តាន់ ម៉េងលី**	អត្តលេខ ០៣៣១៤ នាយការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង
០៤-អនុសេនីយ៍ឯក **សន ស្រ៊ុម**	អត្តលេខ ០១១៦៦៣ នាយរងការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង
០៥-អនុសេនីយ៍ឯក **ឡាង លន់**	អត្តលេខ ៦៣០៦០ អធិការរងក្រុងតាខ្មៅ ស្នងការដ្ឋាននគរបាលខេត្តកណ្តាល
០៦-អនុសេនីយ៍ទោ **យ៉ោក ម៉ុនធី**	អត្តលេខ ០១៣៩៧១ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ផ្សារឆ្នាំង អធិការដ្ឋាននគរបាលក្រុងកំពង់ឆ្នាំង
០៧-លោក **ខៀវ រិទ្ធី**	អនុប្រធានមន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង
០៨-លោក **ឈួន ចាន់ហាន**	អនុប្រធានមន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង
០៩-លោក **សុខ សុខធាន**	សមាជិកក្រុមការងារចុះជួយស្រុកពញាក្រែក ខេត្តកំពង់ចាម
១០-លោក **សុខ សេខហួត**	សមាជិកក្រុមការងារចុះជួយស្រុកពញាក្រែក ខេត្តកំពង់ចាម
១១-លោក **សុខ សីហា**	សមាជិកក្រុមការងារចុះជួយស្រុកពញាក្រែក ខេត្តកំពង់ចាម
១២-លោក **ខែម ម៉ុនថៃ**	មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
១៣-លោក **តាន់ គីមហួត**	មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
១៤-លោក **គង់ ស៊ីឌី**	មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
១៥-លោក **ស្រី សោភ័ណ**	មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
១៦-លោក **ប៊ុស ចំរើន**	មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

p

១៧-លោក អ៊ុំ ឃួន សប្បុរសជនរាជធានីភ្នំពេញ
១៨-លោក ពេជ្រ ឫទ្ធី សប្បុរសជនរាជធានីភ្នំពេញ
១៩-វរសេនីយ៍ទោ សារិន សុវណ្ណ អត្តលេខ ០៨៤៤៨៨ ជំនួយការនាយកដ្ឋានប្រេងឥន្ធនៈ ក្រសួងការពារជាតិ
២០-អនុសេនីយ៍ឯក ខិន ទុច អត្តលេខ ០៤៣៤៩២ ជំនួយការកងស្ពាបនាស្ពាន ផ្តល់ កងពលតូចលេខ៧១៧(កពជ)
២១-អនុសេនីយ៍ឯក គន្ធ វណ្ណដារ៉ាវីន អត្តលេខ ០២៤៧៩៧ ជំនួយការអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
២២-វរសេនីយ៍ទោ អឿម វណ្ណី អត្តលេខ ១១៩១៥ ស្នងការរងនគរបាលខេត្តកំពង់ចាម
២៣-វរសេនីយ៍ត្រី ខិន សំអឺន អត្តលេខ ០៨៨៥១ នាយការិយាល័យស្ថិតិ អត្តសញ្ញាណប័ណ្ណ ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម
២៤-អនុសេនីយ៍ឯក ឈឹម គួច អត្តលេខ ០៦៦១២៥ មេបញ្ជាការរងកងអនុសេនាធំ ក្រសួងការពារជាតិ
២៥-អនុសេនីយ៍ឯក ស៊ិន រីណា អត្តលេខ ០១១២០១ នាយផ្នែក ស្នងការដ្ឋាននគរបាលខេត្តព្រៃវែង
២៦-អនុសេនីយ៍ទោ អ៊ុំ សុគន្ធ អត្តលេខ ៦៤៦៥៣ នាយរងផ្នែកនគរបាលក្រសួងមហាផ្ទៃ
២៧-អនុសេនីយ៍ត្រី ជុំ សុធី អត្តលេខ ១៦៨៤៧ មន្ត្រីនគរបាលវរៈព្រំដែនលេខ៦១៥កំពង់ចាម
២៨-អនុសេនីយ៍ត្រី នា សៀកឃួត អត្តលេខ ៤៧២៥៦ នាយប៉ុស្តិ៍ទួលព្រះឃ្លាំង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម
២៩-ព្រិន្ទបាលឯក ម៉ុង ធីណាយ អត្តលេខ ៥៤១៦៥ មន្ត្រីការិយាល័យអន្តោប្រវេសន៍ ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម
៣០-លោក ហួរ សុខសន្ធា សប្បុរសជនខេត្តសៀមរាប
៣១-វរសេនីយ៍ត្រី ម៉ុល ចាន់ណារិទ្ធ អត្តលេខ ០៤៣១៨២ នាយផ្នែកសរុប អយ្យការយោធា
៣២-អនុសេនីយ៍ឯក ឆាត់ សុជាតិ អត្តលេខ ០១១១៩៨ នាយការិ.សណ្តាប់ធ្នាប់ ស្នងការដ្ឋាននគរបាលខេត្តព្រៃវែង
៣៣-លោក គូ សុជាតិ សប្បុរសជនខេត្តសៀមរាប
៣៤-លោក ប៉ែន ចាន់ថន សប្បុរសជនរាជធានីភ្នំពេញ
៣៥-អនុសេនីយ៍ឯក មុំ រ៉ា អត្តលេខ ១១៤៦៧ នាយរងការិយាល័យនគរបាលអន្តោប្រវេសន៍ ខេត្តកំពង់ចាម
៣៦-អនុសេនីយ៍ឯក គឹម ឡោម អត្តលេខ ២៤៨៩៧ នាយរងការិយាល័យនគរបាលអន្តោប្រវេសន៍ ខេត្តកំពង់ចាម
៣៧-អនុសេនីយ៍ឯក អ៊ុំ សុខន អត្តលេខ ៤៦៩១៩ នាយរងផ្នែកការិយាល័យនគរបាលស្ថិតិ-អត្តសញ្ញាប័ណ្ណ ខេត្តកំពង់ចាម
៣៨-អនុសេនីយ៍ទោ គង់ ស្រ៊ីន អត្តលេខ ១៣៣៣៨១ អនុប្រធាន គ វរការពារព្រំដែនលេខ ២០៤ ខេត្តក្រចេះ.យោធា
៣៩-អនុសេនីយ៍ត្រី ឃួត ទីមាន អត្តលេខ ១៦៩០២ នាយប៉ុស្តិ៍ ខាំភោគ វរការពារព្រំដែនលេខ ៧០១ ខេត្តស្ទឹងត្រែង
៤០-វរសេនីយ៍ត្រី អ៊ុំ សុបំណ្ណណារី អត្តលេខ ៤៦៨៩៩១ នាយរងផ្នែកការិយាល័យនគរបាលស្ថិតិ-អត្តសញ្ញាប័ណ្ណ ខេត្តកំពង់ចាម
៤១-ព្រិន្ទបាលឯក ឈុន ទាសនា អត្តលេខ ៥៦៩៤៧ នាយរងផ្នែកសេនាធិការវរព្រំដែនលេខ ៧០១ ខេត្តស្ទឹងត្រែង
៤២-អនុសេនីយ៍ទោ ចាក់ សុខនី អត្តលេខ ៥៩០៥៩ ជានាយរងផ្នែកបច្ចេកទេស នៃនាយកដ្ឋានអង្គរក្ស នៃក្រសួងមហាផ្ទៃ
៤៣-វរសេនីយ៍ត្រី លាខ គឹមថុន អត្តលេខ ០៧៥៦០ ជានាយរងការិយាល័យសុខាភិបាល នៃអគ្គស្នងការនគរបាលជាតិ
៤៤-លោក ហុន សុផល ក្រុមប្រឹក្សាឃុំដារ ស្រុកមេមត់ ខេត្តកំពង់ចាម
៤៥-អនុសេនីយ៍ត្រី ជា ម៉ិនណា អត្តលេខ ៤០៤៣៦ នាយប៉ុស្តិ៍ជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល
៤៦-ពលបាលឯក សុទ្ធ សម្បត្តិ អត្តលេខ ៤១០៤៤ មន្ត្រីនគរបាលខណ្ឌដង្កោ

ខ-មេដាយប្រាក់ការងារ

១-វរសេនីយ៍ត្រី ខិន សុំអ៊ិនណា អត្តលេខ ០៨៨៥១០ នាយរងការិយាល័យស្ថិតិ អត្តសញ្ញាណប័ណ្ណ ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម
០២-អនុសេនីយ៍ទោ អ៊ុល សុខុម អត្តលេខ ១៩៣៦៧ នាយផ្នែកស្ថិតិ អត្តសញ្ញាណប័ណ្ណ ស្រុកចំការលើ ខេត្តកំពង់ចាម
០៣-អនុសេនីយ៍ត្រី នាំ សៀកឃួតណា អត្តលេខ ៤៧២៥៦៣ នាយរងប៉ុស្តិ៍ទួលព្រះឃ្លាំង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម
